**សុន្ទរកថារបស់ លោក ឌីចា តាយហ្យូ**
**លេខាទី២ ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់គម្រោងកែលម្អផ្លូវ ក្នុងភូមិប៉ាងរលឹម ឃុំអូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន**
ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧

- **សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ**
- **សូមគោរព ឯកឧត្តម កើត សុជា អភិបាលខេត្តប៉ៃលិន**
- **សូមគោរព លោក អ៊ាត សារ៉ាត់ ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះខ្ញុំសប្បាយចិត្តណាស់ ដែលបានមកចូលរួមក្នុងពិធីសម្ពោធគម្រោងកែលម្អផ្លូវ ក្នុងភូមិប៉ាងរលឹម ឃុំអូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ជាមួយវត្តមានរបស់ **ឯកឧត្តម កើត សុជា** អភិបាលខេត្តប៉ៃលិន។

ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ គឺជាវិស័យអាទិភាពមួយនៃជំនួយអភិវឌ្ឍន៍របស់ជប៉ុនសម្រាប់កម្ពុជា ហើយជាក់ស្តែងគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជាច្រើន ត្រូវបានអនុវត្តនៅតាមទីជនបទ។ ឥឡូវនេះ ខ្ញុំពិតជាសប្បាយរីករាយណាស់ ដែលបានឃើញផ្លូវនេះធ្វើបានស្អាតល្អ ក្រោមជំនួយគូសាណូណិ។

ខ្ញុំទទួលស្គាល់ថា ការកែលម្អផ្លូវនេះ នឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណជា ៤,៣០០នាក់ ដែលរស់នៅក្នុងតំបន់នេះ។ គម្រោងនេះត្រូវបានរំពឹងថា នឹងផ្តល់ភាពងាយស្រួលជាងមុនដល់ប្រជាជនក្នុងការធ្វើដំណើរទៅកាន់សាលារៀន មន្ទីរពេទ្យ ផ្សារ និងការដឹកជញ្ជូនកសិផលជាដើម។

ខ្ញុំសង្ឃឹមថា មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តប៉ៃលិន នឹងថែទាំផ្លូវ និងលូនេះឲ្យបានល្អ ដើម្បីអោយប្រជាជនទាំងអស់អាចទទួលបានអត្ថប្រយោជន៍យូរអង្វែង។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះលោក-អ្នកទាំងអស់ ដែលបានរួមចំណែកធ្វើឲ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ផ្លូវនេះ នឹងក្លាយជានិមិត្តរូបនៃមិត្តភាពរវាងប្រទេសយើងទាំងពីរ និងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា៕

**សូមអរគុណ!**